# ការសម្ភាសន៍របស់អ៊ុំស្រី ឈួយកាន់

កះ អ្នកធ្វើការសម្ភាសន៍ លន់ សំប្រាថ្នា ខះ អ្នកដែលត្រូវបានសម្ភាសន៍ ឈួយកាន់

## ពត៌មានសង្ខេបរបស់អ៊ុំស្រីឈួយកាន់

អ៊ុំស្រីឈួយកាន់ មានទីលំនៅបច្ចុប្បន្ននៅភូមិអូរដំបងពីរ ស្រុកសង្កែខេត្តបាត់ដំបង។ ហើយអ៊ុំមានអាយុ៦១ឆ្នាំ។អ៊ុំស្រីមានបងប្អូនចំនួនប្រាំមួយនក់ាស្លាប់អស់បីនាក់នៅសល់បីនាក់ ហើយអ៊ុំជាកូនទីបីនៅក្នុងគ្រុគ្រួសារ។ពួកគាត់ដែលបានស្លាប់គឺស្លាប់ដោយដារជំងឺហើយអ៊ុំស្រីអត់មានបងប្អូនឬក៏សាច់ញាត្តិរបស់អ៊ុំណាម្នាក់ត្រូវបានស្លាប់នៅជំនាន់សម័យប៉ូលពតនោះទេ។ ហើយឪពុកម្ដាយរបស់អ៊ុំស្រី ក៏បានស្លាប់នៅសម័យនេះដែល ពួកគាត់បានស្លាប់ដោយសារតែជំងឺ។ ហើយអ៊ុំស្រីជាស្រ្តីក្រមុំចាស់ អ៊ុំអត់មានគ្រួសារទេ អ៊ុំស្រីរស់នៅជាមួយហ្នឹងបងប្អូនរបស់អ៊ុំសព្វថ្ងៃនេះ។

កះ

ជាដំបូងខ្ញុំសូមជំរាបសួរអ៊ុំខ្ញុំឈ្មោះលន់សំប្រាថ្នាត្រូវបានសាកលវិទ្យាល័យមួយនៅសហរដ្ឋអាមេរិរត្រូវបានគេអញ្ជើញខ្ញុំអោយមកធ្វើការសម្ភាសន៍អ៊ុំទាក់ទងទៅនិងជីវៈប្រវត្តិរបស់អ៊ុំខ្លះៗ នៅសម័យប៉ូលពតដែលអ៊ុំធ្លាប់បានឆ្លងកាត់។ ថាតើវាមានភាពលំបាកយ៉ាងមិចខ្លះចឹងហាអ៊ុំ! ដើម្បីអោយក្មេងៗជំនាន់ក្រោយបានស្គាល់ពីរឿងរ៉ាវទាំងអស់ហ្នឹង។ ហើយអើ...ថ្ងៃនិង ថ្ងៃទី ១៦ ខែបួន ឆ្នាំ២០២០។

អញ្ជឹងតើខ្ញុំអាចសូមការអនុញ្ញាត្តិដើម្បីធ្វើសម្ភាសន៍អ៊ុំបានដែលឬទេអ៊ុំ??

ខះ អើ មិនដឹងនិយាយនិយាយមិចទេហា!៕ នៃពីប៉ុលពតមានស្អីមានតែ...!

កះ ចាំតិចទៀតខ្ញុំមានសំណួរសួរអ៊ុំហើយ។

ខះ អញ្ជឹងសួរមក!

កះ អញ្ជឹងតើអ៊ុំមានឈ្មោះអ្វីដែលអ៊ុំ??

ខះ ឈួយកាន់។

កះ អញ្ជឹងតើអ៊ុំមានឈ្មោះហៅក្រៅទេអ៊ុំ??

ខះ អត់ដឹងទេហា!!?

កះ បាទ!

ខះ ឈ្មោះតែមួយ។

កះ បាទ! អញ្ចឹងតើអ៊ុំមានបានចាំថ្ងៃខែឆ្នាំកំណើតរបស់អ៊ុំបានដែលឬអត់??

ខះ ចាំតើ! មិនដឹងទីប៉ុន្មានអីប៉ុន្មានទេហាស់!! អាញ់ដាក់ឆ្នាំហ្នឹងហើយ។ ឆ្នាំខែចេះតែចាំហើយ ឆ្នាំ ជូត។

កះ អញ្ចឹងបើគិតមកដល់បច្ចុប្បន្នតើអ៊ុំមានអាយុប៉ុន្មានហើយ??

ខះ ៦០, ៦១ឆ្នាំ ហើយឆ្នាំថ្មី, អាយុ ៦១ហើយ។

កះ អញ្ចឹងតើអ៊ុំមានបងប្អូនប៉ុន្មាននាក់ដែលនៅក្នុងគ្រុមគ្រួសារ??

ខះ លើកមុនហ្ន??

កះ និយាយទៅបងប្អូនរបស់អ៊ុំហាស់??

ខះ ប្រាំមួយនាក់! ខូចអស់បីហើយ នៅបី។

កះ អញ្ចឹងតើពួកគាត់មានឈ្មោះអ្វីខ្លះដែលអ៊ុំ??

ខះ ឈ្មោះស្អីទេហា គេសុទដូរឈ្មោះចឹង។ បើគាត់ខូចអស់ហើយ។

កះ អញ្ចឹងតើអ៊ុំស្គាល់របស់ពួកគាត់នៅក្នុងបញ្ជីជាតិរបស់គាត់ដែលអ៊ុំស្គាល់បងប្អូនរបស់អ៊ុំ។

ខះ គេហៅតែក្រៅ! ពេលបែកអស់ទៅ ស្គាល់ឈ្មោះស្គាល់តែឈ្មោះអាញ់, នៃ ឈ្មួយយ៉ង់ ឈ្មួយយ៉ុន និងឯង។

កះ អញ្ចឹងតើប្រាំនាក់និងស្លាប់អស់បីមែនអត់អ៊ុំ??

ខះ ស្លាប់អស់បី៕

កះ អញ្ចឹងតើបីនាក់និង បានស្លាប់ដោយសារអ្វីគេដែលអ៊ុំ??

ខះ ស្លាប់នៅសម័យនេះ៕ គាត់ឈឺ។

កះ គាត់ឈឺ។

ខះ ឈឺ។

កះ អញ្ចឹងអត់មាននណាម្នាក់ស្លាប់នៅក្នុងសម័យប៉ុលពតទេ??

ខះ អត់ទេអត់មានទេ, ម៉ែឪអីគាត់ស្លាប់ ស្លាប់ដោយសារតែគាត់ឈឺ។ សម័យនេះទាំងអស់។

កះ អញ្ចឹងតើអ៊ុំមានបានរៀបអាពាហ៍ពិពាហ៍ដែលឬអត់អ៊ុំ??

ខះ អត់។

កះ ចុះអើ...សមាជិតគ្រុមគ្រួសាររបស់អ៊ុំនិង តើប្រុសប៉ុន្មាននាក់

ហើយស្រីប៉ុន្មាននាក់ដែលអ៊ុំ??

ខ៖ ប្រុសពីរ ស្រីបួន៕

ក៖ ប្រុសពីរ ស្រីបួននាក់៕ អញ្ចឹងតើអ៊ុំជាកូនទីប៉ុន្មាននៅក្នុងគ្រុមគ្រួសាររបស់អ៊ុំ??

ខ៖ ជាកូនទីបី!

ក៖ ចុះអើ...តើពួកគាត់អើ..ចង់និយាយថា

តើពួកគាត់ឥឡូវនិងពួកគាត់ដែលនៅរស់និងតើពួកគាតើធ្វើអ្វីខ្លះដែលអ៊ុំ???

ខ៖ អត់ធ្វើស្អីផង! ធ្វើស្រែ៕ ហាហាហា៕

ក៖ អញ្ចឹងតើពួកគាត់នៅខេត្តបាត់ដំបងយើងនេះតើហី??

ខ៖ នៅខេត្តបាត់ដំបង។ ពីដើមនៅស្រុកកោះក្រឡ។ អោះ..នៅភូមិកោះក្រឡ ស្រុកម៉ោងឬស្សី ពីដើមហ្ន...ពីសង្គមហ្ន!! ហើយសព្វថ្ងៃនេះនៅខេត្តបាត់ដំបង។

ក៖ អញ្ចឹងបច្ចុប្បន្នអ៊ុំបាត់ដំបងមែនទេ។

ខ៖ សួរស្រុកពីមុនពីប៉ុលពតពីអីហ្ន??

ក៖ ហើយចុះ! ហ្នឹងហើយ បើអ៊ុំអាចចាំបាន។

ខ៖ ស្រុកអ៊ុំនៅស្រុក ហាប់ នៅស្រុកហាប់កាលពីប៉ុលពត។

ក៖ ចុះឪពុកម្តាយរបស់អ៊ុំពួកគាត់មានឈ្មោះអ្វីដែលអ៊ុំ??

ខ៖ ឈ្មោះ ហិមគីម្តាយ! ឪពុកឈ្មោះ កែមឈួយ។

ក៖ អញ្ចឹងតើពួកគាត់បានស្លាប់នៅឆ្នាំណាដែល??

ខ៖ យីស អាញ់ភ្លេចហើយហាគាត់មកខូចនីនេះ!! ឆ្នាំប៉ុន្មានទេវើយ។ ខូចទាំងអស់នេះមួយឆ្នាំមួយ។ ឆ្នាំប៉ុន្មានទេវើយ...?

ក៖ បើអត់ចាំក៏អត់អីដែលអ៊ុំ។

ខ៖ កាត់ទើបមកខូចនៅនេះឯង។ ទាំងពីរនាក់ មួយឆ្នាំមួយនាក់។

ក៖ អញ្ចឹងអ៊ុំគិតចេះវិញឆ្នាំ ២ពាន់....ប្រហែលជាប៉ុន្មានឆ្នាំ ចឹងវិញហាស់??

ខ៖ ដប់បី ដប់បួនឆ្នាំហើយដឹង។ ខូចបីបួន ដប់ឆ្នាំហើយ......!!

អាញ់វាមិនបានគិតវាមិនបានចាំ៕

ក៖ ចុះស្រុកកំណើតរបស់ពួកគាតវិញអ៊ុំ??

ខ៖ ហាប់ ស្រុក ហាប់ កោះក្រឡរ អ្នកហាប់។

ក៖ អញ្ចឹងអើ...ឥឡូវហ្នឹងចង់សួរអ៊ុំទាក់ទងពីសម័យប៉ុលពត។ ចង់សួរអ៊ុំថាតើនៅក្នុងសម័យ

ប៉ុលពតនិងតើគេប្រើអោយយើងនិងធ្វើការអ្វីគេខ្លះដែលអ៊ុំ??

ខ៖ ប៉ុលពត! គេអោយលលើកដីលើកអី។ អោយលើកដី

អោយទៅ,,,,អើលើកដីហ្នឹងឯងសម័យប៉ុលពត។

ក៖ អញ្ចឹងក្រៅពីលើកដីហ្នឹងតើអ៊ុំមានបានធញពីអ្វីផ្សេងក្រៅពីនិងដែលឬអត់អ៊ុំ??

ខ៖ មានតែដកស្ទូងអី ដកស្ទូង។

ក៖ អញ្ចឹងអើ...តើនៅក្នុងសម័យប៉ុលពតនិងតើអ៊ុំមានចាំបានតើអ៊ុំមានអាយុប៉ុន្មានឆ្នាំហើយ??

ខ៖ កាលកណឹងប្រហែលជា១៥ឆ្នាំហើយដឹងអាញ់ហ្វ?? កាលប៉ុលពត១៥ ឆ្នាំដឹង

អាញ់នៅកុមារកំព្រារនៅឡើយ។ អូស...អាញ់នៅកុមារជំទង់នៅឡើយ។

ក៖ អញ្ចឹង!!

ខ៖ កាលនៅប៉ុលពតនោះនៅកុមារ។

ក៖ អញ្ចឹងនៅពេលហ្នឹងអ៊ុំនៅជំទង់។ ចុះសម្រាប់អ្នកដែឡមានអាយុ ច្រើនចឹងតើគេប្រើគាត់

អោយធ្វើការងារអ្វីខ្លះ?? ដូចជា ចុះអ៊ុំរៀបរ៉ាប់ថា ក្មេងធ្វើអ្វីគេ?? ហើយតើចាស់ធ្វើអ្វីគេ??

ខ៖ មានតែអាញ់, អាញ់លើកដី ដកស្ទូង ដើរស្ទូង ទូលកណ្ដាប់.. នាំគ្នាដើរទូលកណ្ដាប់តាម

ស្រែហាស់??

ក៖ បាទអ៊ុំ!

ខ៖ គេប្រើចឹងឯង! លើកដីទៅ តែប៉ុនហ្នឹងឯង។

ក៖ ចុះឧទាហរណ៍បងៗរបស់អ៊ុំផ្សេងនិងតើពួកគាត់ធ្វើអ្វីគេដែល??

ខ៖ មានធ្វើ...មានតែធ្វើចឹងឯង ធ្វើស្រែធ្វើអី គេប្រើចឹង។ មានតែធ្វើស្រែធ្វើអី គេមានប្រើអោយ

ទៅណា? ទៅវែអីណាអត់ទេ។ ធ្វើតែស្រែលើកតែអី អីដូចតែគ្នាហ្នឹង។

ក៖ បាទ!

ខ៖ គ្រាន់ទែមួយគេមានប្ដីមានប្រពន្ធគេនៅជាមួយនិងគ្រុមគ្រួសាររបស់គេចឹងទៅ។

យើងគេអោយទៅ កាហ្វតទៅអីស្រេចតែគេប្រើយើងហាស់??

គេប្រើអោយយើងទៅណាយើងទៅនិង

ទៅ៕ ប៉ុលពត មិនអោយនៅជាមួយមិនម៉ែឪយើងឯណាអត់។

ក៖ អញ្ចឹងតើបងប្អូនរបស់អ៊ុំនៅក្នុងសម័យនិងតើបាននៅជុំគ្នាដែលឬអត់អ៊ុំ??

ខ៖ នៅ, នៅផ្សេងគ្នា, បងបែកគ្នា។ បងប្រុសនៅផ្សេងទៅ ហើយអត់ទាន់មានប្រពន្ធផង។

បងប្អូននៅជាមួយ។ គ្មាននៅជាមួយអីទេ។

ជុំអីទេបើយើងកាត់តែព្រៃមិនដែលបាននៅជុំម៉ែឪផល
៕
ក៖ ចុះបងរបស់អ៊ុំហើយនិងអ៊ុំនិងអត់បាននៅជុំជាមួយនិងគ្នាដែល??
ខ៖ គេមានប្តី គេទៅនៅជាមួយគ្រួសារគេផ្សេង។
ក៖ អូ....ចឹងមានន័យនៅក្នុងសម័យប៉ុលពតនិង អ៊ុំហើយនិងបងរបស់អ៊ុំនៅផ្សេងគ្នា??
ខ៖ អើ..គេមានប្តីមានប្រពន្ធគេទៅនៅផ្សេងៗគ្នា។ នៅតែអាញ់បីបួននាក់ បីនាក់នៅជាមួយ
ហើយមែឪគាត់មិនដែលបាននៅជាមួយផងហ្នឹង។ បែកគ្នាតែរហូតហ្នឹងដើរកាត់ព្រៃកាត់អី។
អើ...ដើរលើកដីលើកអីហោះ...!
ក៖ ចុះឪពុកម្តាយរបស់អ៊ុំតើពួកគាត់ធ្វើអ្វីអោយគេដែលកាលហ្នឹង?? គេប្រើលើកដីដែល??
ខ៖ គេប្រើអោយចាំចំការចាំអី ធ្វើចំការ ធ្វើអីចាស់ៗហាស់??
ក៖ បាទ!
ខ៖ មានប្រើធ្វើអ្វីអោយចាំចាំការហ្នឹងឯង។ បលក្មេងៗ គេប្រើអោយទៅលើកដីកលើកអីទៅ។
លើកប្រឡាយលើកអីទៅ។
ក៖ ចុះក្មេងៗហ្វ??
ខ៖ ក្មេងៗហាស់។
ក៖ បាទ!
ខ៖ កុមារៗ៕ កុមារតូចៗទៅគេអោយនៅផ្ទះនៅអីទៅ។
រៀនអីគេ។កាលហ្នឹងគេអោយរៀនដែលតើក្មេងៗ។
ក៖ ហ្នឹងហើយអោយរៀនដែលប៉ុន្តែអត់ដឹងថារៀនអ្វី! ហាហា
ខ៖ អើ...
ក៖ អញ្ជឹងតើ...បើនិយាយពីរឿងរៀន ចូលអោយហើយទៅ។ ចង់សួរអ៊ុំថា
តើអ៊ុំបានរៀនអើ....ដល់ថ្នាក់ទីប៉ុន្មានដែលអ៊ុំ??
ខ៖ បានដល់ថ្នាក់ទីដប់មួយពីសង្គម។ រៀនបានតែពីសង្គមថ្នាក់ទី១១។ ថ្នាក់ទី ១១ ថ្នាក់ទី២
សព្វថ្ងៃ។ មិនទាន់បានរៀនទី១១ ផង រៀនទី ១២នៅឡើយនិង។ ចូលដល់ថ្នាក់ទី ១១
រត់មកនៅស្រុកគេបណ្តោយ។ ពីសង្គមហាស់?

ក៖ បាទ។
ខ៖ ប៉ុលពតអាណាបានរៀន។

កៈ អញ្ចឹងថ្នាក់ទី ១២ ហ្នឹងបើគិតជាឆ្នាំវិញតើបានប៉ុន្មានឆ្នាំ??

ខៈ បានមួយឆ្នាំ។

កៈ បានមួយឆ្នាំ??

ខៈ ហាហា! រៀនបានមួយឆ្នាំ៕

កៈ អញ្ចឹងបើគិតមកដល់ពេលបច្ចុប្បន្នហ្នឹងអ៊ុំរៀនបានចេះអក្សរអីបានដែលឬអត់អ៊ុំ??

ខៈ ចាស! ចេះបានតិចៗបើរៀនអាក់ខរៈកម្មសម័យនេះ។ (ស្តាប់អត់បាន)

កៈ ហើយចុះបងប្អូនរបស់អ៊ុំហ្ន??

ខៈ បងប្អូនក៏រៀន! អាមុនៗអត់បានរៀនទេ។ រៀនតែបងៗ បានតិចៗហ្នឹង។ រៀបានថ្នាក់ប៉ុន្មានទេ។ គ្រាន់តែចេះអានបន្តិចៗ។ មកសម័យនេះបានគេរៀន។

កៈ ចុះអញ្ចឹងចង់សួរអ៊ុំថាក្នុងចំណោមបងប្អូនអ៊ុំទាំងអស់ហ្នឹងតើអ៊ុំធ្លាប់មាននណាម្នាក់ដែលពួកគាត់ធ្លាប់ទៅរស់នៅស្រុកក្រៅដែលឬអត់អ៊ុំ??

ខៈ អត់ទេ។

កៈនៅខ្មែរទាំងអស់??

ខៈ នៅខ្មែរទាំងអស់! អត់ទេ, គេទៅជំរុំ ទៅសិក្សាហាស់??

កៈ បាទ!

ខៈ ដល់ពេលនេះគេមកនៅនេះវិញ។

កៈ អូ...!

ខៈ នៅជំរុំទាំងអស់ហ្នឹង។

កៈ អញ្ចឹងឥឡូវគាត់រួចផុតពីជំរុំគាត់មកនៅនេះវិញមែនដែលឬអត់អ៊ុំ??

ខៈ ទៅនៅគោកត្រុម។

កៈ គោកត្រុម??

ខៈ ទៅនៅគោកត្រុមមួយ ហើយទៅនៅខេត្តត្បូងឃ្មុំមួយ។ គាត់ងាប់បាត់ហើយ។

កៈ ត្បូងឃ្មុំខេត្តកំពង់ចាំហីអ៊ុំ??

ខៈ អើ! កំពង់ចាមយើងពីមុខ។ ពិមុខខេត្តកំពង់ចាមទេ តែបំបែកទៅត្បូងឃ្មុំហាស់??

កៈ បាទអ៊ុំ។

ខៈ អើ!

កៈ អញ្ចឹងចង់សួរអ៊ុំមួយទៀតថា! តើនៅពេលដែលសម័យហ្នឹងនៅពេលដែលអ៊ុំរៀនហ្នឹងតើអ៊ុំ

មានបានលុយទៀរៀនដែលឬអត់អ៊ុំនៅសម័យហ្នឹង??
ខ៖ សម័យណាសម័យអាញ់រៀនពីសង្គមហ្ង??
ក៖ បាទ! អ៊ុំ។
ខ៖ មានលុយមកពីណា! អាណាដែលលក់អីទិញអី រៀននៅសាលាលោក កាលពីសង្គមហាស់??
ក៖ បាទ!
ខ៖ ប៉ុលពតអត់បានទេ ! ប៉ុលពតរវល់តែដើរកាប់ព្រៃកាប់អីលើកដីលើកអីលើកភ្លើលើកប្រឡាយប៉ុលពត គេមិនដែលអោយយើងនៅផ្ទះទេ។ ទូលតែកណ្ដាប់ស្រូវអី ហ្នឹងសម័យប៉ុលពទ យើងមិនបាននៅជុំម៉ែឪបងប្អូនយើងទេ។ ជុំបានទៃដំបូងទេ។
ក៖ បាទ! ចុះអើ តើសាលាដែលអ៊ុំបានរៀនហ្នឹងតើអ៊ុំមានចាំថានៅកន្លែងណា ហើយសាលាហ្នឹងឈ្មោះអ្វីដែលឬអត់??
ខ៖ ហ៊ើ...វត្តលោកហ្ង!!
ក៖ វត្តលោក??
ខ៖ វត្តលោក! ពីដើមរៀននៅសាលាលោកវត្តលោក។នៅកែនផ្ទះហ្នឹងនៅស្រុកអង្គ។ រៀននៅក្នុងវត្តហ្នឹង។
ក៖  អញ្ចឹងតើអ៊ុំមានចាំពីវត្តហ្នឹងដែលឬអត់??
ខ៖ វត្តចាស់ ពីសង្គមគេហៅថាវត្តចាស់។
ក៖ ឈ្មោះវត្តចាស់ហ្ងអ៊ុំ??
ខ៖ វត្តចាស់។
ក៖ នៅស្រុកណាដែល??
ខ៖ នៅស្រុកហាប់។
ក៖ស្រុកហាប់។
ខ៖ នៅភូមិហាប់វត្តចាស់!
ក៖ អើ! អញ្ចឹងតើអ៊ុំនិងធ្លាប់បានធ្វើការងារចំការដៃឡួឬអត់អ៊ុំ? កាលដែលនៅពីក្មេងហាស់??
ខ៖ ពី....?
ក៖និយាយទៅតាំងពីដើមមក!
តើអ៊ុំធ្លាប់បានធ្វើការងារចំការដែលឬអត់??ពីសង្គមដែលបានធ្វើការអីហា??

ខ៖ មើលពីប៉ុលពត, គេប្រើអោយទៅកាប់ព្រៃ...អូស.......គេប្រើអោយទៅលើកដីលើកអី ច្រូតស្ទូវ ច្រូចអីទៅ ទូលកណ្តាប់អីទៅ តែប៉ុនហ្នឹងឯង។

ក៖ ចុះការងារចការដូចជាដាំបន្លែដាំអីតើអ៊ុំធ្លាប់ដាំវាដែលឬអត់??

ខ៖ ធ្វើ! សម័យនេះសម័យនេះ សម័យនេះចេះតែដាំហើយននោងអីទៅ, ពោតអី។ពីប៉ុលពតមានអោយទៅដាំអីមានតែលើកដី លោកប្រឡាយ រ៉ែកគ្រោះ នៅខាងកំហាតអី។ ហើយធ្លាប់ទៅទៅលោកនៅស្ទឹងថ្មីស្ទឹងអី នៅកំហាតហាស់? គេលើកទប់ស្ទឹងថ្មី។

ក៖ អញ្ចឹងខ្ញុំចង់សួរអ៊ុំថា !នៅក្នុងគ្រុមគ្រួសាររបស់អ៊ុំតើមានអ្នកណាគេម្នាក់ដែលគាត់ជាអ្នករកស៊ីអ្វីដែលឬអត់អ៊ុំ??

ខ៖ រកអី!! ពីប៉ុលពតហ្ន??

ក៖ អត់ទេ! ចង់សួរពីដើមមកតើគ្រុមគ្រួសាររបស់អ៊ុំ ជាកសិករ ឬក៏ជាអ្នករកស៊ី។

ខ៖ កសិករទាំងអស់តើ។

ក៖ អត់មានអ្នកណារកស៊ីទេន៏អ៊ុំ??

ខ៖ អត់មានអ្នកណារកស៊ីទេ។ អ្នកស្រែតើពីដើមមកហ្ន ពីសង្គមមកម៉ែឪអ្នកស្រែ។

ក៖ អញ្ចឹង.....!

ខ៖ មិនមានអ្នកធ្វើការអ្វីផង។

ក៖ ចុះការងារអ្វីគេខ្លះដែលអ៊ុំធ្លាប់បានធ្វើតាំងពីដើមកមតើអ៊ុំធ្លាប់បានធ្វើការងារអ្វីខ្លះ??

ខ៖ មានងីក្រៅពីការធ្វើស្រែហាស់?? ក្រោយពីធ្វើស្រែមានតែលក់ដូរអីវ៉ាន់តិចៗហ្នឹង។ លក់នៅសាលារៀនអីតិចៗ។

ក៖ អញ្ចឹងតើអ៊ុំគិតថាជីវតិរបស់អ៊ុំសព្វថ្ងៃ ហើយនិងជីវិតរបស់អ៊ុំកាលពីក្មេងហ្នឹងតើអ៊ុំគិតថាខុសគ្នាយ៉ាងណាដែលអ៊ុំ??

ខ៖ ទេ! ឥឡូវយើងវាបានរកស៊ីរកអីខ្លួណយើង វាគ្រាន់បើជាងមុន នៅពីសង្គតូចៗ យើងមានបានរកអ្វី ហើយនៅជាមួយម៉ែ...!

ក៖ ហើយយ៉ាងមិចទៀតអ៊ុំ?? វាមានភាពលំបាកហើយខុសគ្នាយ៉ងមិចខ្លះទាល់តែអ៊ុំរៀបរ៉ាប់អោយបានច្រើនជាងហ្នឹង។

ខ៖ សម្ន័នេះយើងបានរកស៊ីទៅ យើងបានស៊ីចាយស្រួយ។សម័យប៉ុលពតមានលុយណាចាយ វាអោយបាយស៊ី បបរស៊ី! ប៉ុលពតស៊ីរួម យើងសុម័យនេះយើងរកស៊ីរៀងៗខ្លួន យើងឯងជន។ កាលពីប៉ុលពតស៊ីរួម របស់រួម។

ក៖ ចុះ! តើនៅពីក្មេងរហូតដល់អ៊ុំធំហ្នឹង តើអ៊ុំមានរបស់អ្វីខ្លះ ហើយល្បែងអ្វីខ្លះអ៊ុំតែងតែលេង។ ដែលអ៊ុំចូលចិត្តហាស់??

ខ៖ មិនដែឡលេងទេហា...... មិនដែលបានលេងអ្វីគេផង។ សម័យនេះដឹងតែរកស៊ី លក់ដូរបាត់ហើយ, ពីសម័យហ្នឹងទៅលក់ដូរនៅផ្សារបាត់ហើយ។ ទិញអីវ៉ាន់ តិចៗទៅណាស់។

ក៖ ចុះតើគ្រុមគ្រសាររបស់អ៊ុំហ្នឹងមានអ្នកណាដែល គាត់ចេះប្រើប្រាស់ឧបការណ៍ផ្លែងហើយហ្នឹងលេងភ្លេងមានអ្នកណាចេះទអ៊ុំ?? ឬក៏អត់ទេ??

ខ៖ អត់ចេះទេ!

ក៖ ចុះតើពេលដែលអ៊ុំធំឡើងមានតើអ៊ុំមានដែលធ្លាប់បានចៀង ចេះចៀងហើយហ្នឹងបានស្តាប់បទចរៀងអ្វីដែលឬអត់អ៊ុំ??

ខ៖ ចេះតែស្តាប់សម័យនេះ, ចេះតែមើលទូរទស៍ ហើយមើលឆាកកំប្លែងអីទៅ។

ក៖ ចុះកាលពីមុនហ្ស???

ខ៖ ពីមុនពីដើមមកហ្ស??

ក៖ បាទ!

ខ៖ មានអ្វីមើល។ មានទូរទស៍មកពីណាទើបតែមានសម័យនេះហ្ស! !

ក៖ អូ! អញ្ជឹងនៅសម័យប៉ូលពត! តើសម្រាប់ការងារដែលគេអោយអ៊ុំធ្វើ តើអ៊ុំគិតថាមានការលំបាកដែលឬទេសម្រាប់អ៊ុំឬអត់??

ខ៖ អើ....វាចាំតែលំបាកហើយ! វាមិនដែលមានការងារអ្វីដែលលំបាក។ លើកដីលោកអីវាដែល
ហុបស្រួយដូជាយើងសម័យឥឡូវ, សព្វថ្ងៃហ្នឹងហាស់។

ក៖ បាទ! ដឹងថា អាកាារលំបាកហើយ

ខ៖ លំបាក សម័យប៉ុលតស៊ីកណ្តាក់ស៊ីអីទៅ។ ស៊ីបបរទៅ។ ហ្នឹងប៉ុលពទហាស់៕៕??

ក៖ បាទ! ហ្នឹងហើយ,
ដឹងតែថាវាលំបាកហាលយតែអ៊ុំគិតថាវាលើសពីកម្លាំងដែលយើងត្រូវតែធ្វើវាដែលឬអត់។

ខ៖ ហើម.....យើងធ្វើទៅតាមំម្លាំងរបស់យើងបន្តិចៗ។ យើងតូចធ្វើតាមតូចដែលទៅ។ យើងឈប់ខ្លះអីខ្លះទៅ រែកដី រែកអី សែងដី សែងអី រៀងធូន់យើងឈប់ខ្លះអីឆ្លាស់ៗគ្នាទៅ។

ក៖ អញ្ជឹងបាននយថាគេមិនបង្ខំយើងអោយធ្វើណាស់ណាទែអ៊ុំ??

ខ៖ ហ្នឹងហើយ! យើងឆ្លាត តែធូន់យើងឈប់ខ្លះទៅ។ ឈឺឈប់ខ្លះទៅ, ហើយពីដើម រអៀងឈឺ

គ្រុនញ៉ាក់ណាស់ពីប៉ុលពត, បើគ្រុនយើងឈប់ខ្លះទៅ។
ក៖ អញ្ចឹងមានន័យថាគេ គេអត់ថាអ្វីទេ បើយើងគ្រុនគេអោយយើងឈប់ដែលមែនទេ??
ខ៖ អើ! បើគ្រុនឈប់ហ្នឹងឯងអាណាទៅរួច។
ក៖ អញ្ចឹងតើផ្ទះដែលអ៊ុំរស់នៅកាលពីសម័យប៉ុលពតហ្នឹង! ផ្ទះដែលអ៊ុំរស់នៅជាផ្ទះរបៀបណាដែលអ៊ុំ??
ខ៖ ផ្ទះប៉ុលពតវាដែលផ្ទះធំហាស់! ផ្ទះធ្វើតូចៗម៉ានៅ។ ធ្វើម៉ានៅៗមានទព្យសម្បិត្តិអីប៉ុលពតធ្វើតូចៗទៅចេះតែនាំគ្នាធ្វើទៅណាស់! បើកស្បូវបើកអីទៅ។
ក៖ អូ....! អញ្ចឹងគេមានបើកស្បូវបើកអីអោយយើងទៀត??
ខ៖ មាន! ជ្រកកោងខ្លួនយើងធ្វើខ្លួនយើង។ សរសរខ្វះអីពីដើមព្រៃឈើ។ កាប់ដាក់ឈើខ្លះអីពីប៉ុលពតហូ!!
ក៖ បាទ!
ខ៖ មិនអត់ដូចចេះឯណា។
ក៖ អញ្ចឹងផ្ទះដែលអ៊ុំរស់នៅហ្នឹងតើអ្នកណាជាអ្នកសាងសង់ដែលអ៊ុំ?? សម័យប៉ុលពតហ្នឹងហាស់??
ខ៖ ឪពុកម្ដាយទៅ! ឪពុកយើង នាំគ្នាធ្វើរៀងៗខ្លួនទៅ។ ម្នាក់មួយម្នាក់មួយទៅ។
មួយគ្រួសារ៕
ក៖ បាទ! អញ្ចឹងតើផ្ទះដែលអ៊ុំរស់នៅហ្នឹងតើការសាងសង់អីហ្នឹងតើមានជាងដែលឬអត់អ៊ុំ??
ខ៖ មានទេ! សុទតែខ្លួនយើង។ វែដាក់ វែដាក់នៅជំនាន់ប៉ុលពតហូ។ ហាហាហា
ក៖ ហាហា! អញ្ចឹងសម័យប៉ុលពតផ្ទះដែលអ៊ុំរស់នៅធ្វើអត់មានជាងទេ??
ខ៖ គ្មានជាងទេ, សម័យហ្នឹងណាមានជាងមកពីណា។ ហាហា....
ក៖ ចុះក្នុងការសាងសង់ហ្នឹង! តើអ៊ុំមានបានជួយនៅក្នុងការសាងសង់ហ្នឹងដែលឬអត់??
ខ៖ បានឯណាបើយើងរវល់ដើរលើកដីកាប់រហូត។ តាមសម៉រភូមិ៕ តាមការដ្ឋាន។
ក៖ អញ្ចឹងមានន័យថាអ៊ុំនៅផ្សេង??
ខ៖ អើ! នៅផ្សេងពីម៉ែពីឪ! ទំរាំតែយើងសុំបានគេទៅម្ដងៗ។ នៅបែកពីម៉ែពីឪហ្នឹងឯងពីសម័យប៉ុលពត។
ក៖ អូ...អញ្ចឹងមានន័យថាអ៊ុំសអត់សូវបាននៅផ្ទះទេ??
ខ៖ មិនសូវបាននៅទេ។

កៈ គេ, មានអង្គការរបស់គេ??
ខៈ គេមានអង្គការគេ អោយនៅផ្សេងពីម៉ែពីឪហើយ។
កៈ បាទ! ចុះអាហារដែលគេអោយយើងញាំនៅសម័យហ្នឹងតើមួយថ្ងៃគេអោយយើងញាំប៉ុន្មានពេលដែលអ៊ុំ??
ខៈ ពីរពេល។ មានអីហា មានតែបបរទៅ, ជួនណាបាយទៅ។ ហូបបាយហូបអីទៅ អត់ហ្នឹងកណ្ដក់អីទៅ។
កៈ អញ្ចឹងចង់សួរអ៊ុំថា! នៅសម័យហ្នឹងហេតុអ្វីបានជាហូបខ្វះខាតម្លេះ?? ដោយសារតែយើងធ្វើអត់សូវបានច្រើនឬក៏យ៉ាងមិច?? យើងធ្វើកសិកម្មអត់សូវមាន??
ខៈ សូវគេពេញៗឈ្លាំង! សូវគេពេញៗឈ្លាំងចេះតែបានហើយ។ ធ្វើមួយឆ្នាំ ដូចជាពីរដង ដែលជំនាន់ហ្នឹង។ ធ្វើមួយឆ្នាំពីរដង, ទឹកមិនចេះខ្វះ។ ទឹកប្រឡាយគេហូមកពី ក្រហាត។ ខ្ញុំធ្វើការកសិដ្ឋានមិនសូវបាននៅផ្ទះទេ, ក្មេងៗមិនសូវបាននៅផ្ទះទេ។ តាមតែគ្នា, កុមារគេដាក់ដោយកុមារ នារី គេដាក់ដោយនារី ចឹងទៅណាស់។ ហើយចាស់ៗគេដាក់ដោយចាស់ទៅ មួយកំដុបចឹងទៅណាស់។ គេមិនដាក់, មិនសូវអោយនៅជុំគ្នាទេ។
កៈ ចុះ...!
ខៈចុះគេអោយប្ដីនៅផ្សេងប្រពន្ធនៅផ្សេងទៅ អ្នកណានៅក្មេងៗហាស់??
កៈ បាទ!
ខៈ ចាស់ដូចម៉ែឪអាញ់អី អាណឹងនៅផ្ទះ ចាំចំការចាំអីទៅ, អោយតែមានចំការអីគេអោយដាំអីអី យកមកអោយ ក្នុងការដ្ឋានគេំក្នុងក្រុម ក្នុងភូមិគេទៅណាស់!?
កៈ បាទ!
ខៈ ចាស់ៗនៅផ្ទះ គេធ្វើបបរធ្វើអីចែកទៅ។
កៈ បាទ!
ខៈ ហើយដល់ពេលឆ្អិនគេហៅទៅបើកបបរទៅ៕
កៈ អញ្ចឹងតើពេទ្យនៅសម័យហ្នឹង តើមានពរទ្យដែលឬអត់អ៊ុំ??
ខៈ មាន! ប៉ុន្តែពេទ្យអត់រៀនហូ!! កម្មម៉ាភិបាលអី ពេទ្យក្មេងៗប្រហែលហែងអីហ្នឹង។ សុទតែពេទ្យ។
កៈ ប៉ុន្តែអត់មានចំណេះចំនាញ??
ខៈ មានអី! ចាក់ទឹកដូងចាក់ទឹកអី។ មានថ្នាំឯណា ថ្នាំ គ្រាប់ៗដូចដំឡូងចឹង។

មានថ្នាំពេទ្យអីល្អ! ត្រាំធ្វើខ្លួនឯងល្វីងចង់ងាប់។ សម័យប៉ុលពតវាហើម ជំនាន់ហ្នឹងវាហើយដៃហើមជើង។ សម័យហ្នឹងសំប្បុរហើមដៃហើយជើង។ ហើមខ្លួនជំនាន់ប៉ុលពតហាស់??
ក៖ បាទ!
ខ៖ អាញ់អីហើម៕ ស៊ីៗបបរហើមទៅ។
ក៖ អើ! ម៉េចបានហើយចឹងអ៊ុំអាហ្នឹង?? ហាហា!
ខ៖ អាណាដឹងជំនាន់ហ្នឹង។ ស៊ីបបរ ស៊ីអី!
ក៖ បាទ! ហើយចឹងតើនៅក្នុងគ្រុមគ្រួសាររបស់អ៊ុំហ្នឹងតើមាននណាចេះ ជំនាញ ជំនាញដូចជាត្បាញកន្ត្រក់ត្បាញអីដែលឬអត់អ៊ុំ??
ខ៖ អត់ទេ! ដូចជាអត់ទេ នាំគ្នា ត្បាញសំបុកមួយ ម្នាក់មួយម្នាក់មួយ។ គេត្បាញអោយពួកនារីត្បាញអោយ។ ដាក់បាយដាក់អី៕
ក៖ បាទ!
ខ៖ ចឹងជំនាន់ហ្នឹង។
ក៖ ចុះកាលដែលអ៊ុំនៅពីក្មេងហ្នឹង តើអ៊ុំធ្លាប់មានក្តីស្រម៉ៃថា ពេលធំឡើងហ្នឹងតើអ៊ុំមានដែលធ្លាប់ថាចង់ធ្វើអ្វីមួយដែលឬអត់អ៊ុំ??
ខ៖ អត់! បើមិនបានរៀនចេះដឹងផង។
ក៖ ចុះអើ....កាលពីអ៊ុំនៅក្មេងងហ្នឹងអ៊ុំមានធ្លាប់មានក្តីស្រម៉ៃថា...ពេលធំឡើងហ្នឹងតើអ៊ុំមានធ្លាប់ចង់ធ្វើអ្វីមួយដែលឬអត់អ៊ុំ??
ខ៖ អត់នបើមិនបានរៀនចេះដឹងផង។ សម័យធ្វើអ្វីបើមិនដែលរៀនចេះហ្នឹងគេ!??
ក៖ អញ្ចឹងចង់អោយអ៊ុំរៀបរ៉ាប់ពីសម័យប៉ុលពតហ្នឹង ឬក៏ក្នុងជីវិតរបស់អ៊ុំហ្នឹង តើពេលណាមួយដែលលំបាកជាងគេហាស់?? លំបាកវេទនាជាងគេហាស់?? ថ្ងៃមួយដែលអ៊ុំគិតថាពិបាក៕
ខ៖ មិនដឹងទេហា! សព្វថ្ងៃក៏មិនស្រួយប៉ុនម៉ាណដែល។ ពិបាករកសុីដែល, បើមិនរកយើងបានអីស៊ី?? ទាល់តែយើងរកសម័យនេះហាស់។ កាលពីប៉ុលពតយើងធ្វើការអោយគេបានយើងបានស៊ី! ហាហាហា។ ដល់ពេលយើងសព្វថ្ងៃយើងវាឯងជន។
ក៖ បាទ!
ខ៖ ពីសម័យប៉ុលពតយើងវារួម យើងគ្មានលុយចាយ។ សម័យប៉ុលពតគ្មានអ្នកណាចាយលុយទេ។
ក៖ ប៉ុន្តែចង់សួរអ៊ុំថា មួយជីវិតរបស់យើងតែងតែមានថ្ងៃមួយដែលលំបាកហើយ មែនដែលឬ

អត់អ៊ុំ??
ខ៖ អើ...លំបាករហូតហ្នឹង។ សម័យហ្នឹងយើងនៅតែលំបាក យើងមានអ្វីបើយើងមិនរក??
ដល់តែយើងរកបានយើងមានលុយចាយ។ ដល់ពេលដែលអត់យើងមានអី។
ក៖ អញ្ចឹងចុះបើសិនជាគេអោយអ៊ុំ! បើគេអោយប្រៀបធៀបជីវិតរបស់អ៊ុំ កាលពីក្មេងហើយនិងបច្ចុប្បន្នតើមានភាពខុសគ្នាយ៉ាងម៉េចដែលអ៊ុំ??
ខ៖ វា...សព្វថ្ងៃវាស្រួយដើររកទៅ វាមិនហាត់អ្នកណាស្តីអោយ។ សម័យនេះយើងទៅរកទៅ។
ក៖ សម័យនេះទៅរក!!
ខ៖ អើ..វាគ្មានអ្នកណាស្តីអោយយើង យើងចង់ទៅរកស៊ីរកទៅ, យើងចង់ទៅធ្វើក៏បាន។ សម័យប៉ុលពតគេប្រើយើង បើយើងមិនទៅវាពិបាកដែលហ្នឹងហាស់!! តែគេអោយមុខទៅណាទៅហ្នឹងហើយ។ សម័យនេះបើយើងមិនទៅ ក៏គ្មានអ្នកណាមកបង្ខំយើង។ យើងចង់ដេក ដេកទៅ យើងចង់ដើរ ដើរទៅសម័យនេះ។ អោយតែយើងមានលុយចាយខ្លួនយើង។
ក៖ បាទ! ហើយបើចុះ បើសិនជាអ៊ុំ មិញពីក្មេងមកហាស់?? ចឹងបើសិនជានិយាយពីសម័យប៉ុលពតហើយហ្នឹងសម័យបច្ចុប្បន្នខុសគ្នាយ៉ាងម៉េចដែលទៅអ៊ុំ??
ខ៖ ខុសយើងវាមិនហាត់។ យើងវាបានស៊ីឆ្ងាញ់ ស៊ីស្រួយ.....សម័យនេះណ៎....! យើងកាលពីប៉ុលពតយើងពិបាកស៊ីបបរ ស៊ីកណ្តក់ស៊ីអីហាស់??
ក៖ បាទ! ហ្នឹងហើយអ៊ុំត្រូវហើយ។
ខ៖ ប៉ុនហ្នឹងឯង! សម័យនេះយើងវាបានស៊ីឆ្ងាញ់ៗ។
ក៖ បាទ!
ខ៖ វាគ្រាន់តែថាយើងវាមិនមានផ្ទះអីនៅឯងជន ហើយដីអី។ និយាយទៅប៉ុលពតវារួមទាំងអស់ហ្នឹង។
ក៖ បាទ! ល្អហើយចង់សួរអ៊ុំមួយទៀតថាអើ....តើនៅក្នុងសម័យប៉ុលពតហ្នឹងតើអ៊ុំមានដែលបានឃើញគេសម្លាប់មនុស្សឬក៏មនុស្សដែលគេសម្លាប់ហើយដែលឬអត់??
ខ៖ អាញ់មិនដែលឃើញទេ! អារឿងសម្លាប់មនុស្សមិនដែលឃើញទេ, ឮតែគេល្បីសម្លាប់ហាស់!??
ក៖ បាទអ៊ុំ!
ខ៖ តែបើអោយឃើញគេយកទៅសម្លាប់អីអត់ដែលទេ។ អត់ដឹងទេ, គ្រាន់តែថាឮតែគេនិយាយដែលហ្នឹងហាស់ សម្លាប់ៗ។

ក៖ អញ្ចឹង.....!
ខ៖ យើងវាមិនដឹងហាស់ៗ គេយកទៅសម្លាប់នៅឯណាអីឯណា...គ្រាន់តែសម្លាប់យើងដឹង ហើយគ្រាន់តែមិនដែលឃើញ។
ក៖ បាទអ៊ំ! គេមិនអោយយើងឃើញ។
ខ៖ សម្លាប់មិនអោយយើងឃើញ! គេយកទៅទាំងគ្រួសារ ទាំងគ្រួសារគេយកទៅសម្លាប់ហាស់! គ្រួសាររបស់អ៊ុំ អត់មានអ្នកណាយកទៅផង។ អត់មានអ្នកណាយកទៅសម្លាប់ផង។ គ្មានទេ អត់មានម៉ាក់មួយទេ កាលពីប៉ុលពតហ្ង..ទាំងក្មួយទាំងបងទាំងប្អូនទាំងអស់ អត់មានអ្នកណាសម្លាប់ម៉ាក់មួយទេ។
ក៖ អញ្ចឹង..
ខ៖ ជំនាន់ប៉ុលពត។
ក៖ បាទ! អញ្ចឹងដូចអ៊ុំនិយាយមិញ អ៊ុំនៅស្រុកភូមិចឹងយើងអត់ដែលឃើញទេ។ ចុះទាហរណ៍យើង អ៊ុំនៅ នៅចឹងស្រាប់តែបាត់មនុស្សម្នាក់នោះចឹង តើអ៊ុំមានធ្លាប់ដែលឃើញអញ្ចឹងដែលឬអត់??
ខ៖ គេហៅ! ទៅគេហៅយកទៅ។ គេមកហៅយកទៅសម្លាប់។ មួយគ្រួសារមួយគ្រួសារគេយកទៅទាំងអស់។ ថាយកទៅដាំចំការ យកទៅធ្វើចំការ យកទៅគេសម្លាប់ចោលអស់។ យកទៅគ្មានអ្នកណារស់ផង សម្លាប់ចោលទាំងអស់។
ក៖ បាទ!
ខ៖ ដូចអ្នកផ្ទះអ៊ុំអី អត់មានអ្នកណាហៅផង, ពួកនេះអត់មានអ្នកណាហៅទៅសម្លាប់ផងមួយគ្រួសារ។
ក៖ អញ្ចឹងតើអ៊ុំមានដឹងថា តើពេលហ្នឹងហេតុអ្វីគេសម្លាប់អ្នកទាំងអស់ហ្នឹងដែលឬអត់អ៊ុំ??
ខ៖ មិនដឹង។ ហាហាហា អត់ដឹងទេ។
ក៖ យើងធ្វើខុសអ្វីមួយឬក៏យ៉ាងម៉េចដែល??
ខ៖ យើងមិនដឹងហៅសម្លាប់ទាំងគ្រួសារ! ហៅសម្លាប់ទាំងគ្រួសារទាំងគ្រួសារ។ ដឹងគេធ្វើអ្វីតាំងពីដើមមក។
ក៖ អញ្ចឹងសម្លៀកបំពាក់ដែលអ៊ុំបានស្លៀកពាក់ពីជំនាន់ប៉ុលពតហ្នឹងតើមានភាពគ្រាប់គ្រាន់ដែលឬទេអ៊ុំ??
ខ៖ អើ...ស្លៀកខ្មៅពាកើខ្មៅហើយគេបើកអោយរហូតដែលហា....គេបើកអោយ ដូចជាស្បែក

ជើងអីទៅ ស្បែកជើងខ្មៅៗហាស់?? ស្បែកជើងកង់ឡាន។

ក៖ ស្បែកជើង....អូរចឹង...!

ខ៖ កន្សែងទៅ សំពត់ទៅ អ្នកដើរចឹងគេរអែងបើកអោយណាស់។ ស្លៀកមួយកំប្លែពីកំប្លែគេបើកអោយ។ សំពតខោអាវទៅ។

ក៖ អញ្ជឹងតើស្លៀកជើងពីសម័យហ្នឹងខុសពីសម័យបច្ចុប្បន្នមែនដែលឬទេអ៊ុំ??

ខ៖ អើ...គេហៅថាស្បែកជើងអីទេកាលហ្នឹង.....ស្បែកជើងកង់ឡានហ្នឹងឯង។

ក៖ អញ្ជឹងតើស្បែកជើងហ្នឹងគេកាត់ពីកង់ឡាន ជាយកមកធ្វើមែនអ៊ុំ??

ខ៖ ស្បែកជើងហ្នឹងដូចជាមិនមែនសាច់កង់ឡាន អាញ់មើលទៅ។ ដូចជាទន់ៗ ខ្មៅៗហាស់??

ក៖ បាទ!

ខ៖ ស្អាតៗ ដែលហ្នឹងហាស់! សុទតែមានខ្សែព័ទជើងអីហ្ន....កន្សែងទៅ...វាសំពត់អាវ សុទតែខ្មៅទាំងអស់គេបើកអោយ។

ក៖ បាទ!

ខ៖ កន្សែងពណ៌ខៀវក្រឡាល្អិតៗ។

ក៖ បាទអ៊ុំ។

ខ៖ អត់ចេះសាកពណ៌ទេ។

ក៖ បាទ! អញ្ជឹងសូម្បីតែកន្សែងពណ៌ខ្មៅដែលអ៊ុំ??

ខ៖ ពណ៌ខៀវ។

ក៖ អញ្ជឹងតើយើងអាចប្រើពណ៌អីផ្សេងបានដែលឬអត់??

ខ៖ ពណ៌ខៀវហើយហ្នឹងពណ៌ស្វាយគេបើកអោយហាស់??

ក៖ ចុះខោអាវយើងអាចស្លៀក...?

ខ៖ ខ្មៅ!

ក៖ គឺខ្មៅ??

ខ៖ ខោអាវដឹងតែខ្មៅហើយ។ ខោអាវមានក្រឡាគេដែលប៉ុន្តែពណ៌ខ្មៅៗ។

ក៖ ក្រឡា..?

ខ៖ ពណ៌ខ្មៅៗ អាវ...អីខ្មៅ។

ក៖ អញ្ជឹងមានន័យថានៅសម័យហ្នឹង តើយើងអាចស្លៀកពាក់អ្វីផ្សេងពីខ្មៅបានដែឡឬអត់អ៊ុំ??

ក៖ អាណាគេអោយស្លៀក មានសារ៉ុងណា មានតែខ្មៅទាំងអស់។
ខ៖ ស្លៀកពាក់ខ្មៅ កម្មម៉ាភិបាលក៏ខ្មៅ ខ្មៅទាំងអស់។
ក៖ ចុះបើសួរពីជីវិតរបស់អ៊ុំ...អើនៅ ពេលដែលអ៊ុំសប្បាយជាងគេ, ចាប់ផ្តើមថ្ងៃមួយថា អ៊ុំមានថ្ងៃមួយដែលអ៊ុំគិតថាអ៊ុំសប្បាយចិត្តដែលឬអត់អ៊ុំ??
ខ៖ ទេ...វាទើបធំ រៀនដឹងសម័យនេះ។ សព្វថ្ងៃនេះក៏វាមិនសូវជាកើតទុកប៉ុន្មានដែល។ កើតទុកតែរឿងឈឺ។ ហាហាហាហា។ អារឿងសប្បាយវាចេះតែសប្បាយខ្លះហើយ។ អាណាកើយទុករហូតរើយ...! តែយើងវាឈឺ យ៉ាប់អាយើងវាឈឺតើរាល់ថ្ងៃ។
ក៖ អញ្ចឹងបើចង់អោយអ៊ុំឥឡូវ...ឥឡូវខ្ញុំចង់អោយអ៊ុំរៀបរ៉ាប់ថា ជីវិតរបស់អ៊ុំតាំងពីក្មេងមក ដំណើរជីវិតរបស់អ៊ុំឆ្លងកាត់អ្វីខ្លះ ហើយធ្វើយ៉ាងម៉េចបានជាអ៊ុំរុងរឿងរហូតមកដល់សព្វថ្ងៃចឹង??
តើអ៊ុំអាចរៀបរ៉ាប់បានដែលឬទេ??
ខ៖ សម័យពីសង្គមឆ្លងកាត់គ្រាន់។
ក៖ បាទ!
ខ៖ ដល់សម័យប៉ុលពត, ឆ្លងកាត់នៃ....យើងទៅប្រើ កាប់លើកប្រឡាយលើកអីហាស់?? ជីកប្រឡាយជីកអីនៅសម័យប៉ុលពត។ ដល់ពេលសម័យនេះ៧៩ហាស់??
ក៖ បាទ!
ខ៖ ហ្នឹងនិយាយសម័យនេះ។ គេប្រើទៅកាប់ព្រៃ ទៅកាប់អី តាមស្រុកលើ។ គេប្រើទៅកាប់ព្រៃ អូ...ច្រើនកន្លែងណាស់...តាំងពីព្រៃសំឡូត រហូតដល់ជិតប៉ៃលិនអីរួច កំពីងពួយប្រើទៅលើក នេះហាស់!! លើកប្រោឡាយកំពីងពួយអីទៅ កាយប្រឡាយកាយអី។ ប្រើទៅកាប់ព្រៃខាង, គេហៅអី ក្រហែនកំពីងពួយឯនោះ...សម័យមុនកាប់ព្រៃហាស់ យើងយួនចូលមករួច រត់គ្រាប់ហូ...សម័យមុនគេបាញ់គ្នា ខ្មែរក្រហមអីបាញ់មិនរត់។
ក៖ ហើយចុះ....
ខ៖ មានគ្រាប់ផ្លោងគ្រាប់អីណាសម័យនេះហូ!!
ក៖ រហូតតមកម៉េចទៀតដែលអ៊ុំ?? រហូតមកដល់សម័យនេះតើអ៊ុំធ្លាប់បានទៅរស់នៅឯណាខ្លះ??
ខ៖ សម័យនេះឈប់បាញ់ហើយ។ មិនដែលនៅឯណាផងនៅតែអូរដំបងហ្នឹង។ មិនដែលទៅនៅណា មកនៅអូរដំបងហ្នឹងប៉ុនដោយ។ នៅឯអូរដំបងហើយបានមកនៅនេះហូ។ ៧៩គេប្រើទៅកាប់ព្រៃ មកនៅនេះមានអ្នកណាប្រើ។

កៈ អញ្ជឹងតាំងពីក្មេងមកតើអ៊ុំធ្លាប់បានប្តូរទីកន្លែងរស់នៅប៉ុន្មានកន្លែងហើយអ៊ុំ??

ខៈ តាំងពីក្មេងមកហ្ន??

កៈ បាទ!

ខៈ នៅឯហាប់,,, អូ ច្រើនកន្លែងហា!!

កៈ បាទហ្នឹង!

ខៈ នៅពីសង្គមចាស់ នៅស្រុកហាប់ មករត់ពី៧៥ មកនៅឯភូមិវត្ត តាមិម។ ចេញពីវត្តតាមិមគេជំលៀសមកនៅចំការសំរោង។ គេបាញ់គ្នា។ ចេញពីចំការសំរោងទៅនៅហាប់វិញ។ ទៅហាប់ហើយបានមកនៅអូរដំបងវិញ។ ប៉ុនហ្នឹងឯង។

កៈ អើ...ចុះអើ..តើអ៊ុំមានដឹងថា អ៊ុំចាប់ផ្តើមចេះជំនាញហ្នឹង ចាប់ផ្តើមចេះចំអិនហូបនៅពេលណាដែលអ៊ុំ??

ខៈ អត់ចេះផង! អាញមិនសូវចេះធ្វើម្ហូបទេ។ អត់ចេះធ្វើស៊ីទេ។ ហាហាហា វាមិនសូវដែលបាននៅដាំបាយដាំទឹកអី។

អញ្ជឹងអើ...បើសិនជាចង់អោយអ៊ុំពិពណ៌នាឬក៏និយាយពីជីវិតអ្នកដែលរស់នៅសម័យប៉ុលពតតើអ៊ុំនិយាយដូចថា អាចនិយាយបានថា មនុស្សសម័យហ្នឹងនិយាយពីការរស់នៅមានអើ...ការរស់នៅយ៉ាងមិចដែលអ៊ុំ??

ខៈ មោនដឹងរស់នៅយ៉ាងម៉េចទេហា ប៉ុលពត ព្រោះវា មិនចេះស្រួយប៉ុន្មានទេ ស៊ី គេប្រើគេអី។ លើកដីលើកអីទៅ! វាដែលស្រួយយើងសម័យនេះហាស់?? វា...គ្រាន់តែថាយើងវាគ្មានលុយគ្មានអីដើរទៅ គេប្រើទៅណាទៅហ្នឹងហើយ។ ចុះអ៊ុំមានដឹងទេថា ចុះម៉េចសម័យហ្នឹងស្រាប់តែមាន អើ...ប៉ុលពតកើតមាននៅសម័យហ្នឹងអ៊ុំ??

ខៈ មិនដឹងដែលស្រាប់តែឃើញគេជំលៀស! មកពប្រឹ ពព្រើក។

កៈ ដល់ពេលជំលៀសមិចបានជាគេគ្រាប់គ្រងយើងបាន នៅស្រុកៗគេមកមកគ្រាប់គ្រងយើងម៉ងឬក៏យ៉ាងម៉េចអ៊ុំ??

ខៈ វាមិនដឹងហាស់ អាញ់មិនសូវដឹងទេ។

កៈ អញ្ជឹងអើ....

ខៈ ត្បិតតែចាស់មែនតែអាញ់វាមិនសូវដឹងទេ។ តែគេមិចគឺចឹងឯងវាតាមតែគេទៅ។ គេទៅស្អីយើងចឹងទៅ។

កៈ អញ្ជឹង!

ខ៖ គេរត់រត់ហ្នឹងគេទៅ។
ក៖ អញ្ចឹងចង់សួរអ៊ុំថា នៅពេលដែលចប់ពីសម័យប៉ុលពតហ្នឹងតើគ្រុមគ្រួសាររបស់អ៊ុំបានជួបជុំគ្នាទាំងអស់វិញដែលឬអត់អ៊ុំ??
ខ៖ ជួបនៅជំរុះមួយ។ ជួបប៉ុន្តែនៅជំរុះមួយគ្រួសារ។
ក៖ អញ្ចឹងតើបានចប់ភ្លាមហ្នឹងបានជួបគ្នាម៉ងឬក៏ម៉េចដែលអ៊ុំ??
ខ៖ និយាយទៅ, ទៅជំរុំប៉ុនដោយមួយគ្រួសារហ្នឹងទៅជំរុំ។ ប៉ុន្មានគ្រួសារនៅជួបជុំគ្នា។ បងប្អូននៅជុំគ្នា។
ក៖ អញ្ចឹងបានន័យថាអត់មានបាត់សមាជិកគ្រុមគ្រួសារណាម្នាក់ទេ??
ខ៖ អត់មានទេ! ទើបបាត់សម័យនេះឯង៕
ក៖ បាទ!
ខ៖ នៅប៉ុលពតអត់មានទេបងៗទើបតែខូចនៅសម័យនេះទេ។ ឈឺទៅ មានត្រូវគ្រាប់។
ក៖ បាទអ៊ុំអរគុណច្រើន ដូចថាសំណួរដែលអ៊ុំចង់សួរខ្ញុំនៅថ្ងៃហ្នឹង គឺមានតែប៉ុនហ្នឹងទេ។ ហើយសូមអរគុណអ៊ុំសម្រាប់ការចំណាយពេលវេលារបស់អ៊ុំដែលបានផ្តល់ជូន អើ...ពេលវេលាអោយខ្ញុំធ្វើការសម្ភាសន៍ណាអ៊ុំ។ សូមអរគុណអ៊ុំច្រើនណាអ៊ុំ៕